**គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា**

**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**

ADHOC – BCV-CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CJR- CSD - CWCC - GENEROUS - HROTP
IDA_KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - OUTREACH – PDP - PJJ - TASK FORCE - VIGILANCE
#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh

# សេចក្តីថ្លែងការណ៍

## គណៈកម្មាធិការប្រព្រឹត្តិកម្ម អំពាវនាវឱ្យមានដំណោះស្រាយទៅលើករណីលោកជំទាវ មូ សុខហួរ

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា（CHRAC）ដែលជាសម្ព័ន្ធមានសមាជិកជា អង្គការ-សមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ២៣ សូមសំដែងនូវក្តីកង្វល់ចំពោះវិធានការចាប់បង្ខំដាក់ពន្ធនាគារដោយអាជ្ញាធរកម្ពុជាដល់លោកជំទាវ មូ សុខហួរ សមាជិកសភាមកពីគណបក្ស សម រង្ស៊ី ប្រសិនបើលោកជំទាវមិនព្រមបង់ប្រាក់ពិន័យ ដែលចៅក្រមសាលាដំបូងរាជធានីភ្នំពេញបានចេញសាលក្រមទៅលើបណ្តឹង “បរិហារកេរ្តិ៍” សម្តេចនាយករដ្ឋមន្ត្រី នាពេលកន្លងមក។

ទាក់ទិននឹងករណីខាងលើនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម សង្កេតឃើញថា ដោយសារតែករណីខាងលើនេះជាករណីនយោបាយ កើតឡើងរវាងលោកជំទាវអ្នកតំណាងរាស្ត្រ មូ សុខហួរ និងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ហេតុដូចនេះ ក្នុងនាមជាអង្គការសង្គមស៊ីវិល ដែលបានតាមដានលើករណីនេះ យើងសូមស្នើសុំឱ្យមានដំណោះស្រាយបែបនយោបាយមួយ ដែលភាគីទាំងសង្ខាងអាចទទួលយកបាន ដើម្បីចៀសវាងនូវការប៉ះពាល់នូវមុខមាត់ និង កិត្តិយសរបស់ប្រព័ន្ធយុត្តិធម៌ជាតិ ក៏ដូចជាអ្នកនយោបាយ ផងដែរ។

ដោយសារតែករណីមួយនេះ ជាករណីនយោបាយ គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ឃើញថា តុលាការអាចនឹងមានជំរើសផ្សេងទៀតដែលមិនប៉ះពាល់ដល់ការដាក់គុកបង្ខំរូបរាងកាយលោកជំទាវ មូ សុខហួរ។ ទី១- តុលាការ អាចស្នើឱ្យមានការកាត់ប្រាក់បៀវត្សរបស់លោកជំទាវ មូ សុខហួរ ពីស្ថាប័នរដ្ឋសភា ជាស្ថាប័នដែលលោកជំទាវកំពុងបំរើការនៅក្នុងក៏រិតអប្បបរមា ដើម្បីយកប្រាក់បៀវត្សដែលកាត់នោះទៅបង់ជាប្រាក់ពិន័យសំរាប់សម្តេចនាយករដ្ឋមន្ត្រី និងសំរាប់ជាថវិការដ្ឋ។ ទី២- យើងសូមស្នើសុំដល់សម្តេចនាយករដ្ឋមន្ត្រី មេត្តាលើកលែងមិនយកប្រាក់ពិន័យ និងប្រាក់សំណងជំងឺចិត្ត ពីលោក ជំទាវ មូ សុខហួរ ដោយសារតែកិត្តិយសរបស់លោក ត្រូវបានស្តារនៅក្នុងករណីនេះ តាមរយៈការកាត់សេចក្តីរបស់តុលាការ បញ្ចប់រួចទៅហើយ។ ដូចនេះ ការធ្វើបែបនេះ គឺដើម្បីចៀសផុតពីការដាក់គុកបង្ខំរូបរាងកាយដល់លោកជំទាវ មូ សុខហួរ នៅក្នុងករណីមួយនេះ ហើយក៏ដើម្បីឱ្យទំនាស់នយោបាយរវាងភាគីទាំងពីរ បានបញ្ចប់ទៅដោយរលូនផងដែរ។

*ភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០*

☏ **សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង:**

| | | |
|---|---|---|
| លោក ហង្ស ឆាយា | ប្រធានសំរបសំរួល CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខ: ០១២ ៨៦៥ ៩១០ |
| លោក សុក សំអឿន | នាយកប្រតិបត្តិអង្គការ CDP | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| លោក នី ចរិយា | ប្រធានកម្មវិធីសមាគមអាដហុក | ទូរស័ព្ទលេខ: ០១១ ២៧៤ ៩៥៩ |
| លោកស្រី ស៊ុន ចាន់សែន | ប្រធានសមាគម KYA | ទូរស័ព្ទលេខ: ០១៧ ៧៨៨ ៩៥៥ |
| លោកស្រី សយ សារាវឌ្ឍនី | នាយិកាប្រតិបត្តិអង្គការ CWCC | ទូរស័ព្ទលេខ: ០៩២ ៩៩៣ ៣៥៨ |